# តំបន់ផ្ទៃរងទឹកភ្លៀងខាងលើស្ទឹងសែន A1 & A4i



**ខេត្ត** : ព្រះវិហារ និង សៀមរាប

**ស្រុក** : ជាំក្សាន្ត គូលេន ត្បែងមានជ័យ ជ័យសែន និង ស្វាយលើ

**ផ្ទៃដី ( ហិកតា)** : ៥៣៣.៧៤៨

**រយៈកំពស់ ( ម៉ែត្រ)** : ៣៦ ដល់ ៨០២

**កូអរដោនេចំណុចកណ្ដាល** : ១៤°00´ជ ១០៤°៤៤´ក

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះរួមមានផ្ទៃរងទឹកភ្លៀងនៃស្ទឹងសែនផ្នែកខាងលើ ។ រុក្ខជាតិនៅក្នុងតំបន់នេះគ្របដណ្ដប់លើសលប់ដោយព្រៃរបោះ (មានលំដាប់ថ្នាក់ឈានទៅរកព្រៃពាក់កណ្ដាលស្រោងនៅប៉ែកខាងលិច) និង មានតំបន់ដីសើមមានទឹកជាអចិន្ត្រៃយ៍ និង តាមរដូវកាល ព្រមទាំងវាលស្មៅ ។ តំបន់ភាគច្រើនក្នុងតំបន់ IBA នេះ គឺជាវាលទំនាបលិចទឹក ហើយនៅក្នុងរដូវវស្សា តំបន់នេះត្រូវលិចទឹក រីឯនៅក្នុងរដូវប្រាំង ទឹកមាននៅតាមតែផ្លូវទឹកមួយចំនួន ដូចជាស្ទឹងសែន និង ដៃធំៗរបស់វា និង តាមបឹងនានា ។ នៅតាមផ្លូវទឹកទាំងនោះមានព្រៃពាក់កណ្ដាលស្រោង និង ព្រៃឫស្សីក្រាស់ៗដុះរាយប៉ាយ ។ តំបន់នេះភាគច្រើនស្ថិតនៅក្នុងដែនជំរកសត្វព្រៃគូលេនព្រហ្មទេព ។ តំបន់ IBA នេះ បានទ្រទ្រង់តំបន់ពងកូនរបស់ស្មោញក្រៅពីតំបន់បឹងទន្លេសាប ហើយក៏ជាតំបន់ពងកូនយ៉ាងសំខាន់របស់ក្រៀល និង ត្រដក់តូចផងដែរ ។ លើសពីនេះទៀត ប្រភេទសត្វទទួលរងការគំរាមកំហែង និង ជិតគំរាមកំហែងជាច្រើនត្រូវបានកត់ត្រាពីតំបន់នេះ រួមមានត្រយ៉ងយក្ស ត្រយ៉ងចំកំកស ត្រដក់ធំ អង្កត់ខ្មៅ និង អកត្រីក្បាលប្រផេះ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ក្ងោក | Green Peafowl | *Pavo muticus* | A1 |
| ក្រៀល | Sarus Crane | *Grus antigone* | A1 |
| ចាបពួកទ្រូងលឿង | Asian Golden Weaver | *Ploceus hypoxanthus* | A1 |
| ត្មាតភ្លើង | Red-headed Vulture | *Sarcogyps calvus* | A1 |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 |
| ត្រដក់ធំ | Greater Adjutant | *Leptoptilos dubius* | A1 |
| ត្រយ៉ងចំកំកស | White-shouldered Ibis | *Pseudibis davisoni* | A1 |
| ត្រយ៉ងយក្ស | Giant Ibis | *Pseudibis gigantea* | A1 |
| ស្មោញ | Darter | *Anhinga melanogaster* | A1 |
| អកខ្មៅដីសើម | Greater Spotted Eagle | *Aquila clanga* | A1 |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 |
| អង្កត់ខ្មៅ | Black-necked Stork | *Ephippiorhynchus asiaticus* | A1 |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបបួនប្រភេទរស់នៅក្នុងប្រភេទព្រៃរបោះ (សូមមើលតារាង ឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

រញ្ជីប្រផេះ ស្វាត្រោស ស្វាក្តាម ស្វាព្រាម និង ទោចម្កុដ ។

**ថនិកសត្វ និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក**

រមាំង ខ្ទីង និង ទន្សោង ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

អណ្តើកបិទមុខស្នូកខ្មៅ អណ្តើកសោមញី អណ្តើកក្របីក្បាលលឿង អណ្តើកព្រិច និង កន្ធាយអាស៊ី ។

**ការគំរាមកំហែងលើជីវៈចំរុះ**

មានការតាំងទីលំនៅយ៉ាងច្រើននៅក្នុងតំបន់នេះ រួមមានទីរួមខេត្តត្បែងមានជ័យ ទីរួមស្រុកជាំក្សាន្ត និង ភូមិតាកឹង (ជាភូមិថ្មី)ដែលបង្កើតឡើងនៅឆ្នាំ១៩៩៩ ។ កាលពីឆ្នាំកន្លងទៅ អ្នកភូមិនេះបានប្រមូលយកពងកូនស្មោញពីតំបន់នេះ ហើយកន្លែងពងកូនសត្វស្លាបធំៗក្នុងតំបន់នេះក៏ប្រឈមមុខនឹងការគំរាមកំហែងស្រដៀងគ្នានេះដែរ ជាពិសេសក្រៀលដែលធ្វើសំបុកនៅលើដី និង មានតំលៃផ្នែកពាណិជ្ជកម្ម ព្រមទាំងមានតម្រូវការពីប្រទេសថៃ ។ ការគំរាមកំហែងចំបងនាពេលអនាគតលើជីវៈចំរុះក្នុងតំបន់នេះ រួមមានជនអន្តោប្រវេសន៍ (ដោយមានការអភិវឌ្ឍន៍ផ្លូវថ្នល់តាមខេត្ត) ការពង្រីកដីកសិកម្ម និង ការកើនឡើងនៃសកម្មភាពប្រមាញ់តាមរយៈមនុស្សចំណូលស្រុកថ្មី ។

**អនុសាសន៍**

ការដៅលើផែនទីនូវរាល់តំបន់ដីសើម និង តំបន់ពងកូនសំខាន់ៗរបស់សត្វព្រៃ និង កន្លែងដែលមានមនុស្សរស់នៅក្នុងតំបន់ IBA ទាំងមូលគួរតែត្រូវធ្វើឡើង ។ ការងារនេះនឹងតម្រូវឱ្យមានការសិក្សាស្រាវជ្រាវបន្ថែម ហើយយកទិន្នន័យទាំងនោះមកប្រើប្រាស់សម្រាប់ការធ្វើផែនការអភិរក្ស ។

ផ្តួចផ្តើមដំណើរការនៃការធ្វើផែនការអភិរក្សជាមួយមន្ត្រីធ្វើការនៅក្នុងដែនជំរកសត្វព្រៃ និង ស្ថាប័នពាក់ព័ន្ធដោយផ្អែកលើលទ្ធផលខាងលើ ។ ការបឹងប្រែងគួរតែត្រូវធ្វើឡើងដើម្បីធានាបានការទទួលស្គាល់នៃផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ និង ថ្នាក់ខេត្តខាងលើ ។

ធ្វើការវិភាគអំពីតម្រូវការនៃដែនជំរកសត្វព្រៃ និង បុគ្គលិកបម្រើការទីនោះ ដើម្បីឱ្យដឹងថា សមត្ថភាពរបស់ពួកគាត់អាចត្រូវបានពង្រឹងបានសមរម្យ និង គ្រប់គ្រាន់ ។

ការអនុវត្តន៍ច្បាប់ និង សកម្មភាពល្បាតនាពេលបច្ចុប្បន្នរបស់សត្តរក្សនៅក្នុងដែនជំរកសត្វគូលេនព្រហ្មទេពគួរតែបន្ត និង ពង្រីកឱ្យបាននូវទូទាំងតំបន់សខាន់ៗ ។ សកម្មភាពទាំងនេះគួរតែផ្តោតលើការត្រួតពិនិត្យនៃការនេសាទខុសច្បាប់ ការប្រមូលយកពងកូន និង ការប្រែក្លាយ ឬ ការថយចុះប្រភេទទីជំរកដុះតាមប្រព័ន្ធទន្លេ ។

ការផ្តើមគំនិតនៃការបង្កើតក្រុមអភិរក្សនៅតាមមូលដ្ឋាន ដើម្បីការពារកន្លែងពងកូនរបស់ស្មោញគួរតែមានការផ្គត់ផ្គង់បន្តទៀត និង ពង្រីកបន្ថែមទៅតំបន់ផ្សេងៗទៀត ។

ការតាំងទីលំនៅខុសច្បាប់របស់អ្នកចំណូលស្រុកថ្មី និង ការទន្ទ្រានយកដីនៅក្នុងដែនជំរកសត្វព្រៃគូលេនព្រហ្មទេពគួរតែត្រូវបានហាមឃាត់ ជាពិសេសទាក់ទងទៅនឹងការតាំងទីលំនៅឡើងវិញតាមផែនការគ្រោងទុករបស់អតីតទាហានរំសាយ ។

## ឯកសារយោង


Barzen, J. (2001) Waterbirds and wetlands of northern Cambodia. *Bugle* 27(4): 1-2.

Barzen, J. (2002) Waterbirds and wetlands of northern Cambodia. *Cambodia Bird News* 9:36-38.

Davidson, P., Poole, C. M. and Walston, J. (2001) Cambodia's northern plains: heartland of the Giant Ibis. *World Birdwatch* 23 (4): 15-19.

Goes, F. (2001) L'Ibis Géant, un oiseau légendaire et misanthrope. *Cambodia Bird News* 7: 2-6. (In French.)

Seng Kim Hout and Pech Bunnat (2001) *Survey on Oriental Darter and adjutant colonies.* Unpublished report to the Wildlife Conservation Society Cambodia Program and the BirdLife International Vietnam Programme.

Tan Setha, Pech Bunnat and Song Chansocheat (2002) *Field survey of seasonally flooded wetlands located in the north-west of Preah Vihear province*. Unpublished report, Wildlife Conservation Society, Cambodia.